សម្រាប់ការចុះផ្សាយបន្ទាន់ ៖ ថ្ងៃសុក្រទី ២១ មេសា ២០២០
លេខទំនាក់ទំនងសាលាក្រុង 781-286-8111

# សារលិខិតរបស់សាលាក្រុងជុំវិញ COVID-19៖ ថ្ងៃទី ២១ មេសា ២០២០

## *ការធ្វើតេស្តរកមេរោគ* COVID-19 *នឹងមានផ្តល់ជូនដល់ប្រជាជន* Revere *ទាំងអស់ សាលារដ្ឋទាំងអស់ត្រូវបិទ សម្រាប់ឆ្នាំសិក្សាដែលនៅសល់ អាហារនឹងបន្តចែកជូនដោយឥតគិតថ្លៃនៅ* Rumney Marsh Academy

ថ្ងៃទី ២១ មេសា ២០២០២ – ក្រុមឆ្លើយតបរហ័សប្រចាំក្រុង Revere នៅតែបន្តការងារយ៉ាងសកម្ម ដើម្បីកាត់បន្ថយល្បឿននៃការឆ្លង និងការរាលដាលនៃជំងឺ COVID-19។ ហើយបានរៀបចំវិធានការរួចជាស្រេចដើម្បីទប់ទល់នឹងការឆ្លងនានា។ នៅថ្ងៃនេះ នាយកដ្ឋានសុខាភិបាលរបស់រដ្ឋ Massachusetts បានផ្តល់ដំណឹងមកកាន់ក្រុមសុខាភិបាលប្រចាំក្រុង Revere ថា បានរកឃើញអ្នកឆ្លងមេរោគ COVID-19 សរុបចំនួន ៧៣៣ ករណីនៅក្នុងក្រុង Revere។ ក្នុងនោះមានមនុស្ស ៣០ នាក់បានស្លាប់ និង ១៦២ នាក់បានជាសះស្បើយ។

"ការព្យាករបានបង្ហាញថា យើងខិតជិតដល់ចំណុចកំពូលហើយ។ យើងពិតជាត្រូវការសហការពីប្រជាជនទាំងអស់។ ដូច្នេះហើយសូមស្នាក់នៅផ្ទះ ដើម្បីជួយសង្គ្រោះជីវិត"។ លោកអភិបាល Arrigo និយាយ។

ចាប់ពេលនេះតទៅ ការធ្វើតេស្តនឹងមានផ្តល់ជូនដល់ប្រជាជនទាំងអស់គ្នា នៅទីតាំងចំនួន ២ គឺ Beth Israel Deaconess Chelsea (Broadway) និង MGH Chelsea HealthCare (Everett Ave)។ អ្នកចង់ធ្វើតេស្តមិនតម្រូវឲ្យមានធានារ៉ាប់រងអាយុជីវិត ឬ PCP នោះទេ។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងទៅ 311។

យោងតាមការប្រកាសរបស់លោកអភិបាល Baker បានបញ្ជាក់ថាសាលាទៅអស់នឹងនៅបន្តបិទ រហូតដល់បញ្ចប់ឆ្នាំសិក្សានេះ។ សាលាក្រុង និងគ្រឹះស្ថានសិក្សារដ្ឋទាំងអស់ កំពុងធ្វើការជាមួយគ្នា ដើម្បីទំនាក់ទំនងផ្តល់ព័ត៌មានដល់គ្រួសារសិស្សទាំងអស់ ក៏ដូចជាផ្តល់សម្ភារៈសិក្សា និងបរិក្ខារនានាតាមដែលអាចធ្វើបាន។ ការអាប់ដេតនានានឹងមាននៅលើ RevereK12.org។

ថ្ងៃនេះសាលាក្រុងបានផ្តោតលើប្រតិបត្តិចែកចាយអាហារនៅ Rumney Marsh Academy លើផ្លូវ American Legion Highway។ កម្មវិធីផ្តល់ជូនអាហារដោយឥតគិតថ្លៃនឹងបើកគ្រប់ទីកន្លែងរៀងរាល់យប់ថ្ងៃពុធ ចាប់ពីម៉ោង ៧:០០-៨:០០ យប់ ដោយផ្តល់ដល់ប្រជាជនគ្រប់រូបដែលត្រូវការ។ កម្មវិធីដឹកជញ្ជូនអាហារនឹងបន្តផ្តល់ជូនពីថ្ងៃចន្ទ ដល់ថ្ងៃ សុក្រ ពីម៉ោង ៩:00 ព្រឹកដល់ ២:០០ ថ្ងៃត្រង់ សម្រាប់អ្នកដែលមានវ័យ ៦០ ឆ្នាំឡើងទៅ មនុស្សដែលមានបញ្ហាក្នុងការធ្វើដំណើរ និងអ្នកដែលស្ថិតនៅក្រោមដំណាក់កាលរស់នៅដោយឡែក៕